KO 3308
TSL Box U

# ករណី ឌី ប៊ីន

អាយុ ៣១ ។ ប្រុស ។ ខ្មែរ ។ មានគ្រួសារ ។

- អតីត: បុគ្គលិករោងចក្រកង់ឡាន តាខ្មៅ ផ្នែកគណៈនេយ្យ ។
- បច្ចុប្បន្ន: កម្មករ "ក១" ។

១៩៧១ . ចូលសេ អ៊ី អា នៅក្រសួងសាធារណការភ្នំពេញ ។

អ្នកនាំចូល ឌី ការ៉េត - អ្នកការសែត នគរ ធំ -

អ្នកទទួលស្គាល់ ពិន យ៉ាថៃ - នាយកសាធារណការ -

ឋាន: មេ ក្រុម

ភារកិច្ច ឃោសនា និងកសាងកម្លាំងសេ អ៊ី អា ។

សូមបញ្ជាក់ ថា: ឈ្មោះនេះ ទើបចូលធ្វើការរោងចក្រនេះ នៅឆ្នាំ១៩៧៣ ដូចនេះបញ្ជាចូល សេ អ៊ី អា គ្មានការទាក់ទងនឹងក្រុម សេ អ៊ី អា នៅរោងចក្រនេ ។

សកម្មភាព : ក្រោយ ១៧.៤.៧៥ :

- បានភ្ជាប់ខ្សែរយៈ សេ អ៊ី អា ជាមួយ ពិន ថុន - សេ ៧០ - នៅ ក១ បច្ចុប្បន្ន: ចាប់ខ្លួន - មាននាទីបន្ទាប់ពីឈ្មោះ នេះ ជាមួយ អ៊ុក សាម៉ារឹម - សេ ៧០បច្ចុប្បន្ន: ក១ - ក្តាប់ សេអ៊ីអាទាំងអស់នៅ ក១ ។

- បានរួមប្រជុំគ្នា ជាមួយឈ្មោះ ខាងលើ ជាញឹកញាប់ ដើម្បីចាត់តាំង សេអ៊ី អា នៅក្នុង ក១ ជាក្រុមៗ មានភារកិច្ចនិងលើកផែនការប្រឆាំងបដិវត្ត ។

- បានឃោសនាប្រឆាំងបដិវត្ត ក្នុងចំណោមកម្មករចាស់ អំពីបញ្ហា ហូបតិច ធ្វើការច្រើន បញ្ហាអង្គការបដិវត្តប្រមូលសំភារៈ ជាកម្មសិទ្ធិកម្មករម្នាក់ៗ បញ្ហាកុមារនៅមន្ទីរកុមារ ថាមិនស្អាត មិនល្អ បញ្ហាសិទ្ធិសេរីភាពដើរដេក នឹងថា បដិវត្តគ្មានអនាគត ។

១១.៧៥ • បានរួមប្រជុំលើកផែនការចលនាកម្មករត្រៀមធ្វើបាតុកម្មទាមទារ សំរាកស៊ីចុក ថ្នាំសង្កូវ និងទាមទារទុកកុមារអាយុ ៥ ឆ្នាំឱ្យនៅជាមួយម្តាយក្នុងពេលយប់ នៅខែ ១.៧៦ ។

- បានធ្វើឱ្យខូច :

  - ហ្វ៊ុយស៊ីបទូរបញ្ជា ក្រណាត់មួយ
  - ត្រឡាប់ម៉ាស៊ីន ២
  - កៅស៊ូ អស់មួយចំនួន - ខូចគុណភាព - ។

- បានធ្វើឱ្យម៉ាស៊ីន រអាក់រអួល ជាញឹកញាប់ ។